
នគរអាថ៌ន
ដំណាលស្ដេចនាគ
beyond
ART


តំណាលមកថាមានប្រាសាទអាថ៌កំបាំង លាក់ខ្លួន
កណ្ដាលព្រៃជ្រៅ ដែលផែនទីទៅកាន់ទីនោះគឺស្មុគស្មាញ
និងគ្រោះថ្នាក់បំផុត។ អាថិកំបាំងជាច្រើន បានកប់ទុក
នៅទីដែលកម្រមានមនុស្សទៅដល់នោះ។
beyond
ART





សុខាគឺជា មគ្គុទ្ទេសក៍ទេសចរណ៍ម្នាក់ដែលទទួលបាន
ផែនទីពីអ្នកភូមិបុរាណមួយ ជាមួយនឹងដាវមាសមួយ
ដើម។ បេសកកម្មរបស់គេគឺត្រូវយកដាវមាសមួយដើម
នោះទៅទុកនៅទីតាំងដើមដើម្បីក្ដីសុខរបស់មនុស្សជាតិ


beyond
ART


សុខា
កេនជី
អេមី
អេមី និងកេនជី គឺជាអ្នកផ្សងព្រេងជនជាតិជប៉ុន ពួកគេធ្លាប់ធ្វើដំណើរ ប្រមាណ ៩៨ប្រទេសជុំវិញ ពិភពលោក។ លើកនេះ សុខាបានអញ្ជើញពួកគេមកចូលរួមក្នុងបេសកកម្មមួយ ដើម្បីចូលទៅកាន់ប្រាសាទអាថ៌កំបាំងនោះ។


ដំណើរផ្សងព្រេងចាប់ផ្តើមពីពេលនេះតទៅ។ ខណៈនេះ
គ្រប់គ្នាមើលទៅហាក់សប្បាយរីករាយ និងពេញចិត្តលើ
ដំណើរផ្សងព្រេងនេះខ្លាំងណាស់។ ផ្លូវចូលមើលទៅហាក់
ស្រស់បំព្រង និងពោរពេញដោយស្នាមញញឹមសម្រាប់
ពួកគេទាំង៣នាក់។


beyond
ART


ក្នុងព្រៃអ័ព្ទក្រាស់ សម្លេងធម្មជាតិ បូកសម្លេងរៃ អ្នកទាំង ៣ ហាក់ចូលជ្រៅល្មមនឹងអាចរកផ្លូវទៅវិញមិនឃើញ នោះទេ។ ប៉ុន្តែទឹកមុខ និងកម្លាំងចិត្តរបស់ពួកគេ ដូចជាមិនថមថយសោះឡើយ។


beyond
ART


beyond
ART


ហាកស្អីគេនេះ!


ក្រពើយក្សមួយក្បាលបានហក់មកត្របាក់ កម្ទេចក្បូន
របស់ពួកគេទាំង៣។ រឿងដែលមិននឹកស្មានដល់ក៏បាន
កើតឡើង ក្រពើមួយក្បាលនេះគឺធំសម្បើម សឹងតែធំជាង
ដាយណូស័រយក្សមួយក្បាលទៅទៀត។


សុខាបានដកដាវវមាសមក បម្រុងនឹងតតាំងជាមួយក្រពើ
អាថ៌នមួយក្បាលនោះ។ ក្រពើនោះក៏ប្រកាច់ប្រកិនពេញ
ទឹក ធ្វើឱ្យអេមី និងកេនជីខ្ទាតចេញពីបំណែកក្បូន។ រីឯ
ក្រពើនោះក៏ចាកចេញពីពួកគេទៅបាត់ស្រមោលតែម្តង។


beyond
ART



ក្នុងព្រៃជ្រៅនេះ មើលទៅមិនសាមញ្ញធម្មតាដូចអ្វីដែល
គេបានឃើញក្នុងផែនទីនោះឡើយ។ ទោះបីជាយ៉ាងណា
ក៏ដោយ ពួកគេមើលទៅដូចជាមិនរាថយនោះឡើយ ជា
ពិសេសសុខា គេបានទទួលបេសកកម្មនេះពីអ្នកស្រុក។

beyond ART


ដើរអស់មួយយប់មួយថ្ងៃ អ្នកផ្សងព្រេងទាំងពាន់នាក់ប្រទះ
ឃើញប្រាសាទបុរាណមួយ ដុះកណ្ដាលជ្រោះដីសែនជ្រៅ
ប៉ុន្តែដើម្បីទៅកាន់ទីនោះបាន តម្រូវឱ្យពួកគេចុះទៅក្នុង
ជ្រោះ រួចឡើងពីក្រោមបាតជ្រោះមកវិញ។
beyond ART


beyond
ART


beyond
ART


ចុះតាមជម្រាលភ្នំបានពាក់កណ្ដាល ពស់យក្សមួយក្បាល
កំពុងវាតាមដើមឈើមករកពួកគេ។ លើកនេះសុខា ដឹង
ច្បាស់ថាដាវមាសក្នុងដៃរបស់គេ មានឥទ្ធិពលអស្ចារ្យ
ឈ្នះអស់មារសត្រូវក្នុងព្រៃអាថ៌នមួយនេះ។


beyond
ART


បន្ទាប់ពីពស់យក្សនោះបម្រុងត្របាក់ពួកគេ ស្រាប់តែដាវមាសមួយនោះបញ្ចេញពន្លឺ មានស្ដេចនាគចេញមកតទល់ជាមួយពស់យក្សនោះ រហូតវាដកថយទៅបាត់ ស្រមោលយ៉ាងអាម៉ាស់បំផុត។


beyond
ART


រួចជីវិតពីពស់យក្សមួយក្បាលនោះ អ្នកទាំងពាបានដើរមកដល់ក្លោងទ្វារដើម្បីឡើងទៅប្រាសាទដែលផុសនៅកណ្ដាលជ្រោះមុននេះ។ ហើយទីនេះហើយ គឺជាកន្លែងដែលដាវមាសនេះត្រូវបានមនុស្សអាក្រក់លួចដកយកទៅធ្វើឱ្យពពួកអាថ៌ន ចេញមកគ្រប់គ្រងព្រៃមួយនេះ។
beyond
ART


ចំហាយបិសាច ធ្វើឱ្យដាវមាសបញ្ចេញឫទ្ធិអំណាច រីឯ វល្លិក្រហម ហាក់មានចលនាខុសប្រក្រតី។ មនុស្សដែល មកដល់ទីនេះភាគច្រើនមិនអាចត្រឡប់ទៅវិញបាននោះ ទេ តាំងពីដាវមាសនេះត្រូវបានលួចដកយកទៅ។
beyond
ART


ដាវមាស ចាប់ផ្ដើមបង្ហាញឫទ្ធិ រឹតតែខ្លាំង ធ្វើឱ្យសុខាមិន
អាចគ្រប់គ្រងវាបាន។ មិនត្រឹមតែប៉ុណ្ណោះហាក់ដូចជា
ចង់នាំសុខាទៅកន្លែងណាមួយ។


beyond
ART


ស្តេចនាគ ក៏បានបង្ហាញខ្លួនចេញមក បង្ហាញឫទ្ធិអំណាច ពន្លឺពណ៌មាស ពាសពេញប្រាសាទ មើលទៅសឹងមិនគួរឱ្យជឿ។


វាបានដាស់ឱ្យអាថ៌នដែលលាក់ខ្លួនពួនអត្ថាចាំធ្វើបាប
មនុស្សដែលមកកាន់ទីនេះ។ អាថ៌នមួយនេះរស់នៅក្នុង
រុក្ខជាតិវល្លិចំណាស់មួយ( មិនស្គាល់ឈ្មោះ) វាហុតឈាម
មនុស្សដើម្បីបំពេញអំណាចរបស់វា។ ទោះជាយ៉ាងណា
ក្តី សុខាហាក់ដឹងថាត្រូវធ្វើយ៉ាងណាចំពោះបញ្ហានេះ។
beyond
ART


មិនទាន់បានត្រៀមខ្លួនផង ថ្មជញ្ជាំង និងដំបូលប្រាសាទ
បាក់ធ្លាក់មកក្រោម ធ្វើឱ្យពួកគេទាំង៣ រត់សឹងមិនទាន់។
ក្រឡេកទៅលើឃើញហានុមានមួយធំសម្បើម ហាក់មាន
កំហឹងយ៉ាងខ្លាំងជាមួយអាថ៌ននោះ។
beyond
ART


beyond
ART


beyond
ART


ប្រយុទ្ធមិនទាន់ដឹងឈ្នះចាញ់ផង ដាវមាសបញ្ចេញឫទ្ធិ
ម្តងទៀត លើកសុខាហក់ទៅកាត់ផ្តាច់ឫសរបស់វល្លិ នោះ
វល្លិអាថ៌ននេះហើយ ដែលព្យាយមគ្រប់គ្រងអាថ៌នទាំងអស់
ក្នុងព្រៃមួយនេះ។


ចុងក្រោយដាវមាស បានកំចាត់អាថ៌នោះចេញពីនគរ
របស់ស្តេចនាគបាន ដោយមានការជួយពីហនុមាន។
beyond
ART



ហនុមានបង្ហាញផ្លូវឡើងទៅនគរស្ដេចនាគមដើម្បីឱ្យសុខា
យកដាវមាសទៅដោតកន្លែងដើមវិញ។ រួចពួកគេក៏ធ្វើ
ដំណើរបន្តទៅកាន់នគរនោះ។


ផ្លូវឡើងហាក់ងងឹតខ្លាំង ប៉ុន្តែដាវមាសជាអ្នកបំភ្លឺផ្លូវ និង
នាំពួកគេឡើងឆ្ពោះទៅខាងលើ។



តាមរូបចម្លាក់មួយនេះ ហនុមានគឺជាសេនារបស់ស្ដេចនាគ
ដែលបានរក្សាទីនេះអស់ពេលជាច្រើនពាន់ឆ្នាំមកហើយ។



ទីបំផុតពួកគេក៏បានឡើងមកដល់កំពូលប្រាសាទបានសម្រេច។ ពួកគេបន្តទៅរកទីតាំងដើមរបស់ដាវមាស ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។



ស្ដេចនាគ ក៏បានបង្ហាញខ្លួនចេញមក បង្ហាញឫទ្ធិអំណាច
ពន្លឺពណ៌មាស ពាសពេញប្រាសាទ ដើម្បីបណ្ដេញអាថ៌ន
ចេញពីនគររបស់គេ។


មិនបានប៉ុន្មាន នាគអាថ៌នបានបង្ហាញខ្លួនពីមាត់ល្អាង
ទីបំផុតទើបពួកគេដឹងថា អាថ៌នធំមិនទាន់បានកំចាត់
នោះទេ។ ជំហានបន្ទាប់គឺត្រូវកំចាត់អាថ៌នធំនេះចោល។
beyond
ART


សុខាបានបញ្ជាដាវមាសឱ្យបង្ហាញឫទ្ធិ បណ្ដេញនាគអាថ៌នចេញពីនគរ។


ហនុមានក៏បង្ហាញខ្លួនព្រមគ្នាដើម្បីបណ្ដោញនាគអាថ៌ន
កម្លាំងទាំង២រួមបញ្ចូលគ្នាបង្កើតបានជាឫទ្ធិអំណាចខ្លាំង
អស្ចារ្យ។


beyond
ART


ទីបំផុតកន្លែងរក្សាដាវមាស បានផុសឡើងនៅចំពោះមុខ
សុខា អំណាចស្ដេចនាគមានលើសប្រមាណ ទាញដៃសុខា
ដោតដាវមាសនោះចូលក្នុងលន្លែងដើមវិញ។
beyond
ART


beyond
ART


បន្ទាប់ពីដោតដាវចូលកន្លែងដើមវិញ ភាពវឹកវរក៏ត្រូវបាន បញ្ចប់ បេសកកម្មរបស់ពួកគេក៏បានសម្រេច។ គ្រប់យ៉ាង គឺស្រស់បំព្រង និងមានសន្តិភាព។
beyond ART


ស្ដេចនាគ ក៏បានបង្ហាញខ្លួនចេញមក បង្ហាញឫទ្ធិអំណាច
ពន្លឺពណ៌មាស ពាសពេញប្រាសាទ ម្ដងទៀត។ រួចក៏.....


គ្រប់យ៉ាងគឺអេមឺស្រមៃ នាងចុះពីយន្តហោះភ្លាមមកដល់សណ្ឋាគារភ្លាម ក៏គេងថ្ងៃបន្តិចក៏ស្រាប់តែបានទៅដល់នគរដ៏អស្ចារ្យ ជាមួយបេសកកម្មសឹងមិនគួរឱ្យជឿ។
beyond ART


beyond
ART


ANGKOR WAT
ចុងក្រោយ អេមី និងកេនជីបានជួបជាមួយនឹងសុខា អ្នកកម្លោះមគ្គុទ្ទេសក៍ទេសចរណ៍ដែលនឹងនាំពួកគេទស្សនាដែនដីអច្ឆរិយៈ។
beyond
ART


beyond
ART


beyond
ART



គ្រប់យ៉ាងវាប្រៀបដូចជានិស្ស័យ លើទឹកដីដ៏អស្ចារ្យមួយនេះ។ គ្រប់យ៉ាងដែលកើតក្នុងលោកនេះ មានហេតុ និងផល ហើយគ្រប់យ៉ាងមានរឿងរ៉ាវរបស់វាតាំងពីបុរាណ រហូតដល់ពេលបច្ចុប្បន្ន។


សូមអរគុណ
beyond
ART